ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# គោលនយោបាយ
# ស្តីពី
# ការចុះបញ្ជីដី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិច
# នៅព្រះរាជាណាចក្រកម្ពុជា

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ
នាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩

រៀបចំដោយក្រុមប្រឹក្សាគោលនយោបាយដីធ្លី

# គោលនយោបាយ

## ១.- សេចក្ដីផ្ដើម

ច្បាប់ភូមិបាលឆ្នាំ២០០១ បានទទួលស្គាល់សិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិចនៅព្រះរាជាណាចក្រកម្ពុជាក្នុងការកាន់កាប់ និងប្រើប្រាស់ដីធ្លីជាកម្មសិទ្ធិសមូហភាព ។ ឯកសារបឋមស្ដីពីក្របខណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លីឆ្នាំ២០០២ លើកឡើងអំពី "លក្ខណៈពិសេសខាងសង្គមលើការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិរបស់ជនជាតិដើមភាគតិច និងប្រការដែលមានវិវាទជាញឹកញាប់ពាក់ព័ន្ធនឹងដីធ្លីដែលពួកគាត់រស់នៅ" ។ ដូច្នេះ ការរៀបចំក្របខណ្ឌគតិយុត្តសមស្របមួយសម្រាប់ការងារចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិច ជាប្រការសំខាន់ ដើម្បីពង្រឹងការគ្រប់គ្រងដីធ្លី ព្រៃឈើ និងធនធានធម្មជាតិដទៃទៀតឱ្យមាននិរន្តរភាព និងមានតុល្យភាពក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងការធានាឱ្យសហគមន៍ជនជាតិដើមភាគតិចរក្សាបាននូវវប្បធម៌ ទំនៀមទម្លាប់ និងប្រពៃណីល្អរបស់ខ្លួនទៅអនាគត ។

ជនជាតិដើមភាគតិចមួយភាគធំ រស់នៅតំបន់ខ្ពង់រាបនៃប្រទេសកម្ពុជា ជាប់ព្រំដែនជាមួយប្រទេសវៀតណាម ឡាវ និងថៃ។ ពួកគាត់ច្រើនរស់នៅប្រមូលផ្ដុំតាមប្រពៃណី ប្រកបរបរកសិកម្មតាមទម្លាប់នៃការប្រើប្រាស់ដីជាសមូហភាព ដោយការរៀបចំបែបផែនផលិតកម្មមួយទន់ភ្លន់ ក្នុងការប្រើប្រាស់ពូជ ប្រើប្រាស់កម្លាំងពលកម្ម និងប្រភេទដំណាំនៅលើចំណែកដីខុសៗគ្នាទៅតាមពេលវេលា ធ្វើឱ្យរដូវប្រមូលផលមានរយៈពេលវែង ។ ប៉ុន្តែទោះបីយ៉ាងនេះក្ដី ពួកគាត់តែងជួបប្រទះនូវការខ្វះខាតស្បៀង និងផលដំណាំផ្សេងៗ ជាកត្តាធ្វើឱ្យមានការពឹងផ្អែកស្ទើរទាំងស្រុងទៅលើធនធានធម្មជាតិ ។

## ២.- ចក្ខុវិស័យ និងគោលបំណង

យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ បានចាត់ទុកដីធ្លីជាធនធានធម្មជាតិមូលដ្ឋានមួយសម្រាប់កាត់បន្ថយភាពក្រីក្រ និងសម្រាប់ធានាកំណើនសេដ្ឋកិច្ច ប្រកបដោយសមធម៌នៅជនបទ។

គោលដៅនៃការអភិវឌ្ឍជនជាតិដើមភាគតិច គឺការលើកកម្ពស់កម្រិតជីវភាពរស់នៅតាមរយៈកសិកម្ម ដែលជាផ្នែកមួយដ៏សំខាន់នៃមុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ពួកគាត់។ ដូច្នេះ ការចុះបញ្ជីដីធ្លីជូនសហគមន៍ជនជាតិដើមភាគតិច ជាការធានានូវសុវត្ថិភាពនៃការកាន់កាប់ដីធ្លី ដែលនឹងបង្កលទ្ធភាពឱ្យពួកគាត់ប្រើប្រាស់ដីកាន់តែមានផលិតភាពខ្ពស់។ ប្រព័ន្ធកសិកម្មជឿនលឿនត្រូវតែគិតគូរឱ្យបានសមស្រប ដើម្បីកែលំអកសិកម្មតាមបែបប្រពៃណីទៅជាកសិកម្មបែបប្រពលវប្បកម្ម ការដាំដុះដំណាំដែលផ្ដល់ផលខ្ពស់ ដោយមិនចាំបាច់ធ្វើបន្លាស់ទីដូចពីមុន ហើយផលដែលទទួលបាន ជាផលិតផលមានគុណភាព និងមានទីផ្សារ។ ទោះជាយ៉ាងណា រាល់ការអភិវឌ្ឍមិនគប្បីធ្វើឱ្យប៉ះពាល់ដល់វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណីល្អ និងអត្តសញ្ញាណរបស់ពួកគាត់ឡើយ ។

គោលបំណងរបស់រាជរដ្ឋាភិបាល ក្នុងការចុះបញ្ជីដីជូនសហគមន៍ជនជាតិដើមភាគតិច គឺជាចំណែកមួយនៃដំណើរការគ្រប់គ្រងដីធ្លីនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីធានានូវសុវត្ថិភាពនៃការកាន់កាប់ដីធ្លី និងរួមចំណែកដល់ :

១. ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដោយបង្កលក្ខណៈឱ្យសហគមន៍ជនជាតិដើមភាគតិចមានដីធ្លី និងមានសិទ្ធិប្រើប្រាស់ធនធានធម្មជាតិផ្សេងទៀត សម្រាប់ទ្រទ្រង់ជីវភាពរស់នៅ សន្តិសុខស្បៀង និងអភិវឌ្ឍសហគមន៍របស់ខ្លួន។

២. ការគ្រប់គ្រងដីធ្លីប្រកបដោយនិរន្តរភាព តាមរយៈការកសាងផែនការប្រើប្រាស់ និងគ្រប់គ្រងដីធ្លី ដោយធ្វើឱ្យប្រព័ន្ធកសិកម្មប្រពៃណីរបស់ជនជាតិដើមភាគតិច អាចបន្សាំទៅនឹងការវិវត្តរបស់សង្គមជាតិ ។

៣. ការលុបបំបាត់សកម្មភាពអនាធិបតេយ្យនៃការទន្ទ្រានកាប់រានព្រៃឈើ និងការបង្ខាំងដីទុក ដោយធានាថាសិទ្ធិរបស់សហគមន៍មូលដ្ឋានក្នុងការប្រើប្រាស់ធនធាន ជាទ្រព្យសម្បត្តិសមូហភាពតាមបែបប្រពៃណី ដីធ្លី ព្រៃឈើ និងផ្លូវទឹក នឹងមិនត្រូវបានដកហូត ពីសំណាក់ក្រុមមនុស្សថ្មីណាមួយឡើយ ។

៤. ការថែរក្សាភាពសម្បូរបែបនៃវប្បធម៌ ទំនៀមទម្លាប់ប្រពៃណីល្អក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុញ្ញាតឱ្យសហគមន៍ជនជាតិដើមភាគតិចគ្រប់គ្រងធនធានដីធ្លីក្នុងសហគមន៍ តាមប្រពៃណីរបស់ខ្លួនឱ្យមាននិរន្តរភាព ។

## ៣.- គម្រូវការផ្នែកក្របខណ្ឌគតិយុត្ត

ច្បាប់ភូមិបាលបានកំណត់ថា សហគមន៍ជនជាតិដើមភាគតិច ដែលជាមុខសញ្ញាត្រូវទទួលបាននូវកម្មសិទ្ធិសមូហភាពលើដីរដ្ឋ គឺ "*ជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គម វប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទម្លាប់នៃការប្រើប្រាស់ជាសមូហភាព*" ។ ការចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិចជាកម្មសិទ្ធិសមូហភាព មានលក្ខណៈប្លែកពីការចុះបញ្ជីដីកម្មសិទ្ធិឯកជន ព្រោះការចុះបញ្ជីដីរបស់សហគមន៍ គឺជាការចុះបញ្ជីក្បាលដីទាំងឡាយរបស់សហគមន៍មួយ ដែលមានចំណែកខ្លះជាដីឯកជនរបស់រដ្ឋ និងចំណែកខ្លះទៀតជាដីសាធារណៈរបស់រដ្ឋ ដោយយោងតាមមាត្រា២៥ មាត្រា២៦ និងមាត្រា២២៩ នៃច្បាប់ភូមិបាល និងអនុក្រឹត្យពាក់ព័ន្ធ ។ ក្បាលដីទាំងនោះមានទំហំខុសៗគ្នា និងអាចស្ថិតនៅក្នុងឃុំ សង្កាត់តែមួយ ឬអាចស្ថិតក្នុងឃុំ សង្កាត់ខុសគ្នា។ ដូច្នេះ ក្នុងការចុះបញ្ជីក្បាលដីទាំងឡាយរបស់សហគមន៍ត្រូវមានអនុក្រឹត្យមួយដោយឡែក ដែលបំពេញបន្ថែមទៅលើនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ឬមានលក្ខណៈជាប្រព័ន្ធដែលមានស្រាប់ ។

## ៤.- ដំណើរការចុះបញ្ជីដីសហគមន៍

ដំណើរការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចត្រូវមានលក្ខណៈងាយស្រួល ទាំងផ្នែករដ្ឋបាល ទាំងផ្នែកបច្ចេកទេស និងត្រូវតែមានតម្លាភាព ដោយមានការចូលរួមពីតំណាងសហគមន៍ ពីសមាជិកផ្សេងៗនៃសហគមន៍ និងពីអ្នកជិតខាង ក្នុងការកំណត់ទីតាំងព្រំប្រទល់ដីសហគមន៍នីមួយៗ និងការបិទផ្សាយឯកសារជាសាធារណៈ ។

នៅពេលដែលក្របខណ្ឌគតិយុត្តមិនទាន់មានគ្រប់គ្រាន់សម្រាប់ការចុះបញ្ជីដីធ្លីសហគមន៍ជនជាតិដើមភាគតិច ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក អាចដំណើរការធ្វើអត្តសញ្ញាណកម្ម ធ្វើផែនទី និងធ្វើចំណាត់ថ្នាក់ដីរដ្ឋក្នុងតំបន់នោះ។

សហគមន៍ដែលមានការទទួលស្គាល់តាមផ្លូវច្បាប់ត្រឹមត្រូវហើយ ត្រូវចូលរួមបង្ហាញទីតាំង និងព្រំប្រទល់ក្បាលដីដែលសហគមន៍បាន និងកំពុងកាន់កាប់ ដូចជា ដីប្រើប្រាស់សម្រាប់និវេសនដ្ឋាន ដីស្រែចំការដែលកំពុងប្រើប្រាស់ជាក់ស្តែង ដីដែលសហគមន៍ធ្លាប់បានប្រើប្រាស់ និងបម្រុងទុកសម្រាប់ដូរវេនដំណាំ និងដីផ្សេងៗទៀតដែលធ្លាប់បានប្រើប្រាស់ជាប្រយោជន៍រួមរបស់សហគមន៍ ដូចជា ដីព្រៃកប់ខ្មោច ដីព្រៃអារក្ស ដីព្រៃឈើ និងដីទីតាំងប្រភពទឹក។ ក្នុងករណីដែលទីតាំង និងព្រំប្រទល់ក្បាលដីដែលសហគមន៍មួយបានចង្អុលបង្ហាញនោះ មានការទទួលស្គាល់ដោយអ្នកជិតខាង និងអាជ្ញាធររដ្ឋបាល ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក អាចធ្វើការវិនិច្ឆ័យករណីនីមួយៗទៅតាមការជាក់ស្តែង។ តាមធម្មតា ទីតាំងក្បាលដីដែលសហគមន៍មួយធ្លាប់បានកាន់កាប់ និងប្រើប្រាស់ ឬដីបម្រុងទុកសម្រាប់ការដូរវេនដំណាំជាចម្ការពនេចរតែងមានបន្សល់ទុកនូវស្លាកស្នាម និងភស្តុតាងផ្សេងៗ មានជាអាទិ៍ ស្នាមកូនរុក្ខជាតិដុះជាព្រៃឡើងវិញលើចម្ការចាស់ បន្ទាប់ពីរងការដុតព្រៃដើម្បីធ្វើចម្ការ ឬ/និងគ្រាប់ធញ្ញជាតិដែលសេសសល់ពីការប្រមូលផលនៅរដូវប្រមូលផលលើកមុន។ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក អាចធ្វើការសម្របសម្រួល និងវិនិច្ឆ័យទៅតាមករណីជាក់ស្តែង ក្នុងដំណើរការនៃការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ។ ព្រំប្រទល់ដីរដ្ឋជាប់នឹងក្បាលដីរបស់សហគមន៍ ដែលក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក បានគូសនៅលើផែនទីភូមិ ឬផែនទីឃុំ គឺជាចំណុចព្រំប្រទល់នៃផែនទីបឋមតែប៉ុណ្ណោះ។

ប្រសិនបើអាជ្ញាធររដ្ឋបាលមិនបានទទួលស្គាល់ការអះអាងរបស់សហគមន៍ជនជាតិដើមភាគតិច អំពីទីតាំង ទំហំ និងព្រំប្រទល់ក្បាលដីណាមួយ ក្នុងចំណោមក្បាលដីទាំងឡាយរបស់សហគមន៍ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ត្រូវគូសចំណាំចំណុចព្រំប្រទល់មិនច្បាស់លាស់នោះនៅលើផែនទីភូមិ ឬផែនទីឃុំ (ផែនទីបឋម) សម្រាប់ការចុះត្រួត ពិនិត្យ និងការវិនិច្ឆ័យរបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត។ទោះបីជាមិនទាន់ពេញជាលក្ខណៈច្បាប់ក៏ដោយ ក៏ផែនទីបឋមនេះជាឧបករណ៍បច្ចេកទេសមួយ ដែលនឹងជួយការពារដីរបស់សហគមន៍មិនឱ្យមានការរំលោភ ការទិញ ដូរ ឬការកាប់រានទន្ទ្រានព្រៃបន្តទៀត។

## ៥.  ដីធ្លីដែលមានលក្ខណៈសមស្របសម្រាប់ការចុះបញ្ជីជាកម្មសិទ្ធិសមូហភាព

ច្បាប់ភូមិបាលទទួលស្គាល់សិទ្ធិសហគមន៍ជនជាតិដើមភាគតិច ក្នុងការផ្តួចផ្តើមគំនិត និងការកំណត់ថា ដីធ្លីប្រភេទណាជាដីធ្លីចាំបាច់ដើម្បីចុះបញ្ជីជាកម្មសិទ្ធិសមូហភាព។ មាត្រា២៥ នៃច្បាប់ភូមិបាលចែងថា " *ដីសហគមន៍ជនជាតិដើមភាគតិច មិនមែនមានតែដីដែលបានដាំដុះជាក់ស្តែងនោះទេ ប៉ុន្តែមានដីបម្រុងចាំបាច់ក្នុងការដូរវេនដំណាំថែមទៀត ដែលតម្រូវទៅតាមរបៀបទាញយកផលដែលធ្លាប់ធ្វើកន្លងមក ហើយត្រូវបានទទួលស្គាល់ដោយអាជ្ញាធររដ្ឋបាល។ ការវាស់វែង និងការកំណត់ព្រំប្រទល់នៃអចលនវត្ថុរបស់សហគមន៍ទាំងនោះ ត្រូវកំណត់ទៅតាមស្ថានភ* [illegible]

*ដែលបានអះអាងដោយសហគមន៍ ដោយមានការព្រមព្រៀងពីអ្នកជិតខាង* "។ អាជ្ញាធររដ្ឋបាលពាក់ព័ន្ធនឹងដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច ដែលជាតំណាងស្ថាប័នរដ្ឋនៅក្នុងមូលដ្ឋាន ត្រូវចូលរួមក្នុងដំណើរការកំណត់ព្រំប្រទល់នៃក្បាលដីទាំងអស់ដែលសហគមន៍អះអាងថាជារបស់ខ្លួន។

ដីដែលមានលក្ខណៈសមស្រប សម្រាប់ការចុះបញ្ជីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ រួមមាន ÷

- ដីឯកជនរបស់រដ្ឋដែលមាន ÷
  . ដីដែលសហគមន៍បានរៀបចំនិវេសនដ្ឋាន ( ដីលំនៅឋាន ) និង
  . ដីដែលសហគមន៍ប្រកបរបរកសិកម្មប្រពៃណី ( ដីដាំដុះដាក់ស្តែង និងដីស្រែចម្ការ ) ដែលបានទទួលស្គាល់ដោយអាជ្ញាធររដ្ឋបាល និងមានការព្រមព្រៀងពីអ្នកជិតខាង។
- ដីសាធារណៈរបស់រដ្ឋ ដែលមានការកំណត់ទីតាំង ទំហំ ព្រំប្រទល់ជាក់លាក់ និងសិទ្ធិប្រើប្រាស់ដូចដែលសហគមន៍ធ្លាប់បានអនុវត្តកន្លងមក និងដែលបានចុះបញ្ជីរួចហើយជាមួយរដ្ឋ។ ដីទាំងនោះ មាន ÷
  - ដីបម្រុងចាំបាច់ក្នុងការដូរវេនដំណាំ ដែលបានទទួលស្គាល់ដោយអាជ្ញាធររដ្ឋបាល និងមានការព្រមព្រៀងពីអ្នកជិតខាង
  - ដីព្រៃអារក្ស ដែលអាចមានមួយ ឬច្រើនកន្លែងសម្រាប់សហគមន៍នីមួយៗ គួរមានទំហំសរុបមិនលើសពី ០៧ ( ប្រាំពីរ ) ហិកតា និង
  - ដីព្រៃកប់ខ្មោច (ដីព្រៃបញ្ចុះសព) ដែលអាចមានមួយ ឬច្រើនកន្លែងសម្រាប់សហគមន៍នីមួយៗ គួរមានទំហំសរុបមិនលើសពី ០៧ ( ប្រាំពីរ ) ហិកតា។

ចំណែកដីរដ្ឋក្រៅពីការរៀបរាប់ខាងលើ ត្រូវចុះបញ្ជីជាដីរដ្ឋឱ្យទៅអាជ្ញាធរដែលមានអាណាព្យាបាលកាន់កាប់ដីនោះ តែសហគមន៍ជនជាតិដើមភាគតិចមានសិទ្ធិបន្តការប្រើប្រាស់ និងអាស្រ័យផលតាមទំនៀមទម្លាប់ប្រពៃណី ដូចដែលពួកគាត់ធ្លាប់អនុវត្តកន្លងមក។ ដីទាំងនោះមានដូចជា ដីព្រៃសម្រាប់ប្រមូលអនុផលព្រៃឈើ ដីប្រភពទឹក ។ល។

ដីដែលអនុញ្ញាតឱ្យសហគមន៍ប្រើប្រាស់តាមប្រពៃណីទាំងនេះ ត្រូវកំណត់ទីតាំង ព្រំប្រទល់ និងទំហំ ដោយដាក់សញ្ញាសម្គាល់តាមរូបភាពប្រើប្រាស់។ សហគមន៍មានសិទ្ធិប្រើប្រាស់តាមប្រពៃណី និងត្រូវអនុវត្តតាមច្បាប់ជាធរមានដូចជា ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ច្បាប់ទាក់ទងនឹងវិស័យឧស្សាហកម្ម រ៉ែ និងថាមពល ច្បាប់ស្តីពីជលផល និងការអនុវត្តសកម្មភាពការងាររបស់រដ្ឋ ដែលជាតម្រូវការនៃផលប្រយោជន៍ជាតិ ឬតម្រូវការជាបន្ទាន់របស់ជាតិ។

## ៦.~ សិទ្ធិប្រើប្រាស់ និងការគ្រប់គ្រងដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច

ដីដែលជនជាតិដើមភាគតិចកំពុងកាន់កាប់ និងប្រើប្រាស់ជាសមូហភាព មានចំណែកដីខ្លះជាដីឯកជនរបស់រដ្ឋ និងចំណែកខ្លះទៀតជាដីសាធារណៈរបស់រដ្ឋ។ មាត្រា២៦ នៃច្បាប់ភូមិបាលចែងថា "...កម្មសិទ្ធិសមូហភាពរួមមាន

រាល់សិទ្ធិ និងការការពារកម្មសិទ្ធិដូចកម្មសិទ្ធិឯកជនដែរ។ ប៉ុន្តែសហគមន៍នោះគ្មានសិទ្ធិចាត់ចែងនូវចំណែកណាមួយនៃកម្មសិទ្ធិសមូហភាពដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋឱ្យទៅបុគ្គល ឬក្រុមណាមួយបានឡើយ "។ ដូច្នេះ សហគមន៍ជនជាតិដើមភាគតិចមានសិទ្ធិលើកម្មសិទ្ធិសមូហភាពដូចដែលបានទទួលស្គាល់ដោយច្បាប់ រួមមានសិទ្ធិបន្តមរតក សិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យផល។ មាត្រា២៨ នៃច្បាប់ភូមិបាលក៏បានកំណត់ច្បាស់លាស់ ថា "*គ្មានអាជ្ញាធរណាមួយក្រៅពីសហគមន៍ អាចទទួលបានសិទ្ធិលើអចលនវត្ថុរបស់ជនជាតិដើមភាគតិចបានឡើយ* "។ ដូច្នេះ កម្មសិទ្ធិសមូហភាពរបស់ជនជាតិដើមភាគតិច មិនអាចជាកម្មវត្ថុនៃការលក់ ដូរ ឬផ្ទេរទៅឱ្យអ្នកក្រៅសហគមន៍បានឡើយ លើកលែងតែករណីដែលសមាជិកណាមួយនៃសហគមន៍ចាកចេញពីសហគមន៍ នោះសហគមន៍អាចនឹងត្រូវផ្ទេរជាពិសេសឱ្យពួកគេ នូវចំណែកសមស្របមួយនៃដីដែលប្រើដោយសហគមន៍ និងស្ថិតលើចំណែកដីឯកជនរបស់រដ្ឋ។

ច្បាប់ភូមិបាលមាត្រា២៧ បានចែងថា "*ដើម្បីសម្រួលដល់ការវិវត្តវប្បធម៌ សេដ្ឋកិច្ច និងសង្គមនៃសហគមន៍ជនជាតិដើមភាគតិច និងដើម្បីអនុញ្ញាតឱ្យពួកគេបានចេញដោយសេរីពីសហគមន៍ ឬរួចផុតពីការបង្ខិតបង្ខំ សិទ្ធិនៃកម្មសិទ្ធិឯកត្តជនអាចនឹងត្រូវផ្ទេរជាពិសេសឱ្យពួកគេបាន លើចំណែកសមស្របមួយនៃដីដែលប្រើប្រាស់ដោយសហគមន៍ ប៉ុន្តែចំណែកដីដែលជាកម្មវត្ថុនៃការយកមកធ្វើជាកម្មសិទ្ធិឯកជននោះ មិនអាចជាដីដែលចូលក្នុងនិយមន័យទូទៅនៃទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋទេ* "។

ចំពោះចំណែកដីជាដីសាធារណៈរបស់រដ្ឋ សហគមន៍មានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលតាមប្រពៃណីរបស់ខ្លួនតែប៉ុណ្ណោះ។ ក្នុងករណីដែលសហគមន៍ធ្លាប់បានប្រើប្រាស់ដីផ្សេងទៀតដែលបានចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីរដ្ឋ នោះសហគមន៍ត្រូវធ្វើកិច្ចព្រមព្រៀង ជាមួយស្ថាប័នសាមីដែលមានសមត្ថកិច្ច ឬមានអាណត្តិកាន់កាប់ដីរដ្ឋ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ប្រសិនបើសហគមន៍មានបំណងទទួលខុសត្រូវក្នុងការថែរក្សាការពារទ្រព្យសម្បត្តិរដ្ឋនោះ សម្រាប់សហគមន៍ខ្លួន។

ក្នុងករណីជនជាតិដើមភាគតិចដែលមានដីជាកម្មសិទ្ធិឯកជន ឬបានកាន់កាប់ចំណែកដីជាឯកជនស្របច្បាប់ ហើយមានបំណងចង់ចូលជាសមាជិកសហគមន៍ជនជាតិដើមភាគតិច ត្រូវលះបង់ចំណែកដីឯកជនទាំងនោះ ដោយបញ្ចូលមកក្នុងដីដែលជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍។ ចំណែកដីដែលត្រូវបញ្ចូលទាំងនោះ ត្រូវចាត់ចូលក្នុងចំណែកដីឯកជនរបស់រដ្ឋ។

ដើម្បីធានានូវការអនុវត្តសិទ្ធិ និងការគ្រប់គ្រងដីធ្លីរបស់សហគមន៍ទៅតាមច្បាប់កំណត់ សហគមន៍ត្រូវមានបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនស្តីពីការប្រើប្រាស់ដីធ្លីដែលបានចុះបញ្ជីជាកម្មសិទ្ធិសហគមន៍។ បទបញ្ជានេះត្រូវចែងលម្អិតអំពីសិទ្ធិលើចំណែកនៃប្រភេទដីនីមួយៗ ការចាត់ចែងទ្រព្យរបស់សហគមន៍ក្នុងករណីសហគមន៍រំសាយ និងត្រូវឱ្យស្របទៅនឹងខ្លឹមសារដែលមានចែងក្នុងលក្ខន្តិកៈសហគមន៍។ បទបញ្ជាផ្ទៃក្នុងនេះត្រូវស្របនឹងផែនការប្រើប្រាស់ដី និងត្រូវតម្កល់នៅក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងចម្លងជូនអង្គភាព ឬស្ថាប័នពាក់ព័ន្ធ។

អាជ្ញាធរដែនដី ជាពិសេសក្រុមប្រឹក្សាឃុំ សង្កាត់ និងស្ថាប័នពាក់ព័ន្ធដែលមានកិច្ចព្រមព្រៀងជាមួយសហគមន៍ត្រូវតាមដានត្រួតពិនិត្យរាល់ការគ្រប់គ្រង និងការប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិចដែលពាក់ព័ន្ធនឹងដីព្រៃឈើ តំបន់ការពារធម្មជាតិ តំបន់រ៉ែ និងការអភិវឌ្ឍក្នុងតំបន់ផ្សេងៗទៀត ។ល។ ដើម្បីធានាការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយផលិតភាព និរន្តរភាព និងស្របតាមច្បាប់ ។

## ៧.- សេចក្តីសន្និដ្ឋាន

ការផ្តល់កម្មសិទ្ធិដីធ្លីដល់សហគមន៍ជនជាតិដើមភាគតិច ធ្វើជាកម្មសិទ្ធិសមូហភាព គឺជាការផ្តល់សិទ្ធិស្របច្បាប់ជូនសហគមន៍កាន់កាប់ និងប្រើប្រាស់ដីធ្លី ការធានានូវសុវត្ថិភាពនៃការកាន់កាប់ដីធ្លីសម្រាប់ប្រកបរបរកសិកម្មចិញ្ចឹមជីវិត និងឈានទៅបង្កើនផលកសិកម្មសម្រាប់ទីផ្សារ ។ ការផ្តល់ជំនួយនានាដើម្បីអភិវឌ្ឍកសិកម្មត្រូវមានវិធីសាស្ត្រក្នុងការធ្វើសមាហរណកម្មបច្ចេកទេសទំនើប ដើម្បីឱ្យពួកគាត់អាចទទួលយកបាននូវផលប្រយោជន៍ពីទំនើបកម្ម និងការប្រែប្រួលថ្មី ដោយរក្សានូវអត្តសញ្ញាណវប្បធម៌ និងទំនៀមទម្លាប់ប្រពៃណីល្អរបស់សហគមន៍ ។ សុវត្ថិភាពនៃការកាន់កាប់ដីធ្លីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ ជាការបើកចំហឱ្យមានកាលានុវត្តភាពថ្មីមួយសម្រាប់សហគមន៍ជនជាតិដើមភាគតិច ។

# សន្ទានុក្រម

**ជនជាតិដើមភាគតិច :**

ជាតិពន្ធុដែលរស់នៅក្នុងប្រទេសកម្ពុជាតាំងពីដើមរៀងមក ហើយមានភាសា វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណីរបស់ខ្លួនខុសពីជនជាតិខ្មែរដែលជាប្រជាជាតិស្នូល។ ជនជាតិដើមភាគតិចមាន ព្នង កួយ ទំពួន ចារាយ គ្រឹង ព្រៅ កាវ៉ែត ស្មៀង ក្រោល មិល កាចក់ ព័រ ខោញ ជង សួយ ថ្មូន លុន ស្ទូច រដែ ខិ រអង ស្អុង ល្មឺន ស់រ៉ៃ និងជនជាតិដើមភាគតិចផ្សេងទៀត ។ ជនជាតិដើមភាគតិចទាំងនោះមានរបៀបរស់នៅតាមប្រពៃណី និងមានការដាំដុះលើដីដែលខ្លួនបាន កាន់កាប់តាមក្បួនខ្នាត ទំនៀមទម្លាប់ នៃការប្រើប្រាស់ដីជា សមូហភាព។ បងប្អូនជនជាតិដើមភាគតិចទាំងអស់មានប្រមាណមួយ (០១) ភាគរយនៃប្រជាជនសរុប ហើយរួមរស់ជាមួយជាតិពន្ធុខ្មែរប្រកបដោយសុខដុមរម្យនា ដរាបរៀងមកនៅក្នុងខេត្តមួយចំនួន ដូចជាខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ព្រះវិហារ កំពង់ធំ ស្ទឹងត្រែង ឧត្តរមានជ័យ កំពង់ចាម ពោធិសាត់ កំពង់ស្ពឺ កោះកុង បាត់ដំបង ព្រះសីហនុ បន្ទាយមានជ័យ សៀមរាប និងតំបន់ ផ្សេងទៀត។

**កម្មសិទ្ធិសមូហភាព :** ដីធ្លីដែលជាកម្មសិទ្ធិរួមរបស់សហគមន៍ជនជាតិដើមភាគតិចមួយក្រុម ហើយកម្មសិទ្ធិនេះមិនមែនជាកម្មសិទ្ធិឯកជនដោយឡែកៗរបស់សមាជិកសហគមន៍នោះឡើយ។ សមាជិកសហគមន៍ម្នាក់ៗឬគ្រួសារនីមួយៗនៃសហគមន៍គ្មានសិទ្ធិចាត់ចែងដីជាកម្មសិទ្ធិសមូហភាពនេះទេ។

**ជាតិពន្ធុ** : ក្រុមមនុស្សដែលមានរចនាសម្ព័ន្ធគ្រួសារ សេដ្ឋកិច្ច និងសង្គមដូចគ្នា ហើយមានភាសានិងវប្បធម៌តែមួយរួមគ្នា។

**ដីលំនៅដ្ឋាន** : ដីដែលសមាជិកសហគមន៍ជនជាតិដើមភាគតិចប្រើប្រាស់ដើម្បីសាងសង់ផ្ទះស្នាក់នៅឬរស់នៅជាអចិន្ត្រៃយ៍(និវេសនដ្ឋាន)។

**ដីបំរុងចាំបាច់សម្រាប់ផ្លាស់វេនដំណាំ**
**ឬដីរៀបចំបម្រុងសម្រាប់ចំការពនេរចរ**
**ឬដីចំការវិលជុំ** : ដីដែលសហគមន៍ជនជាតិដើមភាគតិចធ្លាប់បានប្រើប្រាស់កន្លងមកជាស្រែឬចំការក្នុងការផ្លាស់វេនដំណាំតាមប្រពៃណី។

**ដីព្រៃអារក្ស** : ទីកន្លែងដែលសហគមន៍ទុកសម្រាប់បូជាឬសែនព្រេនតាមទំនៀមទម្លាប់ប្រពៃណី។

**ដីព្រៃកប់ខ្មោច** : ទីកន្លែងដែលសហគមន៍ប្រើប្រាស់សម្រាប់បញ្ចុះសពទៅតាមប្រពៃណីរបស់ខ្លួន។

**ទស្សនាទាន** : ការប្រកាន់យកតាមការយល់ឃើញ។

**ទេសចរណ៍សហគមន៍** : គោលនយោបាយជាតិដែលរៀបចំឡើងដោយក្រសួងទេសចរណ៍ សម្រាប់យកទៅអនុវត្តក្នុងសហគមន៍ ដើម្បីអភិវឌ្ឍវិស័យទេសចរណ៍ក្នុងគោលបំណងកាត់បន្ថយភាពក្រីក្ររបស់បងប្អូនជនជាតិដើមភាគតិចនៃសហគមន៍នោះ។

**សហគមន៍ទេសចរណ៍** : សហគមន៍ដែលមានបង្អែកលើវិស័យទេសចរណ៍។

**អាជ្ញាធររដ្ឋបាល** :អាជ្ញាធរមូលដ្ឋាននិងអាជ្ញាធរដែលមានអាណត្តិកាន់កាប់ដីរដ្ឋឬធនធានធម្មជាតិរបស់រដ្ឋក្នុងតំបន់នោះ។

**អាជ្ញាធរប្រពៃណី**

**ឬគណៈកម្មាធិការសហគមន៍**

: ថ្នាក់ដឹកនាំសហគមន៍ដែលត្រូវបានជ្រើសរើសដោយសមាជិកសហគមន៍ទាំងមូលដើម្បីដោះស្រាយបញ្ហាក្នុងសហគមន៍។ វាជាយន្តការមួយសម្រាប់សម្រុះសម្រួលទំនាស់ក្នុងសហគមន៍នៅក្រៅរង្វង់តុលាការ។

**អ្នកជិតខាង** :ប្រជាពលរដ្ឋឬសហគមន៍ទាំងឡាយឬអាជ្ញាធរកាន់កាប់ដីរដ្ឋដែលមានព្រំប្រទល់ដីជាប់នឹងដីរបស់សហគមន៍ដែលបានស្នើសុំចុះបញ្ជីដី។

<u>កំណត់សំគាល់</u>

ជនជាតិភាគតិច : ក្រុមមនុស្សដែលមានសញ្ជាតិខ្មែរ មានភាសា វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី ដោយឡែកផ្ទាល់ខ្លួនហើយពួកគេរស់នៅក្នុងចំណោម ជនជាតិខ្មែរដែលជាប្រជាជាតិស្នូល ។

ប្រជាជាតិស្នូល: ជាតិពន្ធុខ្មែរដែលមានដើមកំណើត និងរស់នៅលើទឹកដីកម្ពុជា តាំងពីរដើមរៀងមក ហើយមានប្រមាណ (៩០) ភាគរយ នៃប្រជាជនសរុប ។